**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ព្រឹទ្ធសភា រដ្ឋសភា ក្រុមប្រឹក្សាធម្មនុញ្ញ

លេខ :.....០១៩.........ព.រ.ក

# សេចក្ដីសម្រេចរួម

## ស្ដីពី

## ការផ្ដល់បន្ថែមប្រាក់បំណាច់មុខងារ ដល់មន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ

**ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា**

**ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា**

**ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញបទបញ្ជាផ្ទៃក្នុង នៃព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញបទបញ្ជាផ្ទៃក្នុង នៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញលទ្ធផលបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានទី១ អនុប្រធានទី២នៃព្រឹទ្ធសភា នីតិកាលទី៣
- បានឃើញលទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី៥ នៃរដ្ឋសភា ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការជ្រើសតាំងរចនាសម្ព័ន្ធថ្នាក់ដឹកនាំរដ្ឋសភា និងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៦/៦១៦ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៦ ស្ដីពីការតែងតាំងប្រធានក្រុមប្រឹក្សាធម្មនុញ្ញ សម្រាប់អាណត្តិ៣ឆ្នាំ លើកទី៧
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៣/០០៧ ចុះថ្ងៃទី១៣ ខែ កុម្ភៈ ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤១៧/០០៤ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ
- បានឃើញសេចក្ដីសម្រេចរួមលេខ ០១ ព.រ.ក ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៤ ស្ដីពីបៀវត្សមូលដ្ឋាននិងប្រាក់បំណាច់ផ្សេងៗរបស់មន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ
- បានឃើញសេចក្ដីសម្រេចរួមលេខ ០១២ ព.រ.ក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៥ ស្ដីពីការកែសម្រួលប្រាក់បំណាច់មុខងាររបស់មន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ
- បានឃើញសេចក្ដីសម្រេចរួមលេខ ០១៥ ព.រ.ក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៧ ស្ដីពីការកែប្រែនិងដំឡើងប្រាក់បំណាច់មុខងាររបស់មន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ/.

# សម្រេច

**មាត្រា១.-**

សេចក្តីសម្រេចនេះ មានគោលដៅកំណត់ការផ្តល់បន្ថែមនូវប្រាក់បំណាច់មុខងារប្រចាំខែដល់មន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ ដូចខាងក្រោម៖

| ល.រ | បរិយាយ | ប្រាក់បន្ថែម | ផ្សេងៗ |
|---|---|---|---|
| ១ | អគ្គនាយក | ៤០.០០០៛០០ | |
| ២ | អគ្គាធិការ | ៥០.០០០៛០០ | |
| ៣ | អគ្គនាយករង | ៤០.០០០៛០០ | |
| ៤ | អគ្គាធិការរង | ៦០.០០០៛០០ | |
| ៥ | ប្រធាននាយកដ្ឋាន | ៤០.០០០៛០០ | |
| ៦ | អនុប្រធាននាយកដ្ឋាន | ៤០.០០០៛០០ | |
| ៧ | ប្រធានការិយាល័យ | ២៤.០០០៛០០ | |
| ៨ | អនុប្រធានការិយាល័យ | ២៤.០០០៛០០ | |
| ៩ | ប្រធានផ្នែក | ២៤.០០០៛០០ | |
| ១០ | មន្ត្រីអភិបាល | ២៤.០០០៛០០ | |
| ១១ | មន្ត្រីឧបការី | ២៤.០០០៛០០ | |
| ១២ | មន្ត្រីលេខាធិការ | ៣៤.០០០៛០០ | |

**មាត្រា២.-**

ការផ្តល់បន្ថែមនូវប្រាក់បំណាច់មុខងារប្រចាំខែដល់មន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិត្រូវចាប់អនុវត្តពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៨ តទៅ។

**មាត្រា៣.-**

អគ្គលេខាធិការព្រឹទ្ធសភា អគ្គលេខាធិការរដ្ឋសភានិងអគ្គលេខាធិការក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវទទួលអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព តាមភារកិច្ចរៀងៗខ្លួន។

ថ្ងៃ [illegible] ខែចេត្រ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ២០១៨

**ប្រធានព្រឹទ្ធសភា** | **ប្រធានរដ្ឋសភា** | **ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ**

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

**សម្តេចអគ្គមហាពញាចក្រី ហេង សំរិន**

**អ៊ឹម ឈុនលឹម**

**កន្លែងទទួល.**
- គណៈកម្មាធិការសេដ្ឋកិច្ចនៃព្រឹទ្ធសភា
- គណៈកម្មាធិការសេដ្ឋកិច្ចនៃរដ្ឋសភា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី

"ដើម្បីជូនជ្រាប និងមុខការ"